ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលជលផល

# កម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹង

# សហគមន៍នេសាទ

## នៅព្រះរាជាណាចក្រកម្ពុជា

រៀបចំដោយរដ្ឋបាលជលផល

ខែមករា ឆ្នាំ២០០៨

បោះពុម្ពឡើងវិញ ឆ្នាំ២០១៨

ខ្លឹមសារនៅក្នុងសៀវភៅនេះជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផលនិង
មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

The contents of this publication are the sole responsibility of Fisheries Administration and can in no way be taken to reflect the views of the European Union.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលជលផល

# កម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹង

# សហគមន៍នេសាទ

# នៅព្រះរាជាណាចក្រកម្ពុជា

រៀបចំដោយរដ្ឋបាលជលផល

ខែ មករា ឆ្នាំ ២០០៨

# មាតិកាអត្ថបទ


អារម្ភកថា.....ក

សេចក្តីសង្ខេប .....គ

**ផ្នែកទី ១ ច្បាប់ស្តីពីផលផលដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ** .....១

ជំពូកទី ១១ សហគមន៍នេសាទ .....៣

**ផ្នែកទី ២ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ** .....៥

**ផ្នែកទី ៣ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ** .....៩

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ .....១២

ជំពូកទី ២ ការបង្កើតសហគមន៍នេសាទ .....១៣

ជំពូកទី ៣ តួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍នេសាទ .....១៤

ជំពូកទី ៤ គណៈកម្មការសហគមន៍នេសាទ .....១៧

ជំពូកទី ៥ ស្ថាប័នទទួលខុសត្រូវ .....១៩

ជំពូកទី ៦ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ .....២០

ជំពូកទី ៧ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ .....២២

ជំពូកទី ៨ ប្រភពហិរញ្ញវត្ថុ .....២៣

ជំពូកទី ៩ ទោសប្បញ្ញត្តិ .....២៣

ជំពូកទី ១០ អវសានប្បញ្ញត្តិ .....២៤

**ផ្នែកទី ៤ ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ** .....២៧

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ .....២៩

ជំពូកទី ២ ការបង្កើត និងភារកិច្ចរបស់ក្រុមស្ថាបនិក .....២៩

ជំពូកទី ៣ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ .....៣១

ជំពូកទី ៤ មហាសន្និបាតសហគមន៍នេសាទ.....៣១

ជំពូកទី ៥ ការបង្កើតសហគមន៍នេសាទ .....៣២

ជំពូកទី ៦ ការកំណត់ទីតាំងកន្លែងនេសាទសហគមន៍ .....៣៤

ជំពូកទី ៧ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ .....៣៥

ជំពូកទី ៨ ការចុះបញ្ជី និងការទទួលស្គាល់សហគមន៍នេសាទ .....៣៦

ជំពូកទី ៩ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ .....៣៦

ជំពូកទី ១០ ការត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ ....................................... ៣៩
ជំពូកទី ១១ ការដោះស្រាយវិវាទ ....................................... ៤០
ជំពូកទី ១២ ការរំសាយសហគមន៍នេសាទ ....................................... ៤១
ជំពូកទី ១៣ អន្តរប្បញ្ញត្តិ ....................................... ៤១
ជំពូកទី ១៤ អវសានប្បញ្ញត្តិ ....................................... ៤២
គំរូលក្ខន្តិកៈសហគមន៍នេសាទ ....................................... ៤៥
ជំពូកទី ១ គោលបំណង និងនាមករណ៍ ....................................... ៤៦
ជំពូកទី ២ លក្ខខណ្ឌនៃការសុំចូលជាសមាជិក កាតព្វកិច្ច និងសិទ្ធិរបស់សមាជិក ....................................... ៤៦
ជំពូកទី ៣ លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក ....................................... ៤៨
ជំពូកទី ៤ របៀបរបបកាន់បញ្ជី និង ឯកសារនានា ....................................... ៤៩
ជំពូកទី ៥ គណៈកម្មការសហគមន៍នេសាទ ....................................... ៥០
ជំពូកទី ៦ របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ....................................... ៥០
ជំពូកទី ៧ មហាសន្និបាតសហគមន៍នេសាទ ....................................... ៥២
ជំពូកទី ៨ ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ....................................... ៥៣
ជំពូកទី ៩ លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ ....................................... ៥៤
ជំពូកទី ១០ នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ....................................... ៥៥
ជំពូកទី ១១ អវសានប្បញ្ញត្តិ....................................... ៥៦
គំរូបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ....................................... ៥៧
គំរូកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ ....................................... ៦៣
គំរូផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ....................................... ៧១

# អារម្ភកថា

វិស័យជលផលនៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាជាវិស័យមួយដែលមានសារៈសំខាន់យ៉ាងធំធេងចំពោះសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ។ សារៈសំខាន់នេះត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រខ្មែរតាំងពីមុនសម័យអង្គរវត្តមកម្ល៉េះ ហើយការគ្រប់គ្រងវិស័យនេះមានការវិវឌ្ឍពីជំនាន់មួយទៅជំនាន់មួយ ស្របតាមស្ថានភាពប្រែប្រួលនៃធនធានធម្មជាតិ នយោបាយ និងការអភិវឌ្ឍសង្គម ។

ដោយមើលឃើញនូវសារប្រយោជន៍ដ៏ធំធេងនេះ ទើបកន្លងមករាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រសមស្របនានាដើម្បីធានានូវការគ្រប់គ្រងវិស័យជលផលឱ្យមានចីរភាព ។ ជាក់ស្តែងកាលពីខែតុលា ឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសធ្វើការកែទម្រង់គោលនយោបាយគ្រប់គ្រងវិស័យជលផល ដោយបានសម្រេចកាត់បន្ថយ និងលុបនាទីឡូត៍នេសាទប្រមាណជាង ៥៦ % នៃផ្ទៃឡូត៍នេសាទសរុបទូទាំងប្រទេស ស្មើនឹង ៥៣៨ ៥២២ ហត. ជូនប្រជាពលរដ្ឋមូលដ្ឋានចូលរួមគ្រប់គ្រង និងប្រើប្រាស់ឱ្យបានគង់វង្ស ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានជម្រុញការរៀបចំសហគមន៍នេសាទឱ្យមានដំណើរការទៅមុខឆាប់រហ័សដើម្បីផ្តល់ឱកាសជូនប្រជាពលរដ្ឋមូលដ្ឋានចូលរួមក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានល្អប្រសើរ ។

បច្ចុប្បន្ននេះ ការគ្រប់គ្រងវិស័យជលផលនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺផ្អែកជាសំខាន់តាមច្បាប់ស្តីពីជលផល ដែលត្រូវបានរៀបចំឡើងស្របតាមការចាំបាច់ និងការអភិវឌ្ឍនៃសង្គមជាតិ ក្នុងនោះមានបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងសហគមន៍នេសាទ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំ និងប្រព្រឹត្តទៅរបស់សហគមន៍នេសាទនៅក្នុងព្រះរាជណាចក្រកម្ពុជា ។ ស្របទៅតាមច្បាប់ស្តីពីជលផល លិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនទៀតពាក់ព័ន្ធនឹងការរៀបចំ និងការគ្រប់គ្រងសហគមន៍នេសាទត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការផងដែរ ។

រដ្ឋបាលជលផលបានផ្តួចផ្តើមរៀបចំចងក្រង និងបោះពុម្ពជាសៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងសហគមន៍នេសាទនេះឡើង ក្នុងគោលបំណងដើម្បីជម្រុញការងាររៀបចំ និងគ្រប់គ្រងសហគមន៍នេសាទឱ្យបានសមស្រប និងទូលំទូលាយ ជាពិសេសគឺដើម្បីផ្តល់នូវភាពងាយស្រួលដល់អ្នកពាក់ព័ន្ធទាំងឡាយដែលបំពេញការងារក្នុងការរៀបចំ និងគ្រប់គ្រងសហគមន៍នេសាទនៅកម្ពុជា ។

រដ្ឋបាលជលផលសូមអធ្យាស្រ័យពីសំណាក់មិត្តអ្នកអាន ចំពោះរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនាពីការចងក្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងសហគមន៍នេសាទនេះ ។ ជាមួយគ្នានេះដែរក៏សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ដែលកន្លងមកបានជួយឧបត្ថម្ភគាំទ្រដល់ការងារគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្នុងការជួយឧបត្ថម្ភចំពោះការបោះពុម្ពកម្រងលិខិតបទដ្ឋានគតិយុត្តិនេះឡើង ។ រដ្ឋបាលជលផលសង្ឃឹមថានឹងទទួលបាននូវកិច្ចសហការ និងការគាំទ្រជាច្រើនថែមទៀតពីបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍វិស័យជលផលឱ្យបានគង់វង្សជារៀងរហូត ដែលជាគុណប្រយោជន៍ ដល់ជាតិមាតុភូមិកម្ពុជារបស់យើង ។

**ណៅ ធួក**

**ប្រធានរដ្ឋបាលជលផល**

# សេចក្តីសង្ខេប

ការគ្រប់គ្រងជលផលតាមបែបសហគមន៍នេសាទនេះ គឺជាគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ឱ្យចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងមានសមធម៌ក្នុងការទទួលនូវផលប្រយោជន៍ពីធនធានទាំងនោះ។ កន្លងមកការរៀបចំសហគមន៍នេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានប្រព្រឹត្តទៅយ៉ាងសកម្ម ដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងមានការគាំទ្រយ៉ាងមុតមាំពីបណ្តាដៃគូអភិវឌ្ឍន៍នានា និងអាជ្ញាធរដែនដី។

មុនឆ្នាំ ២000 ការបង្កើតសហគមន៍នេសាទត្រូវបានធ្វើឡើងនៅតាមបណ្តាខេត្តមួយចំនួនតូចប៉ុណ្ណោះដែលរួមមាន ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តស្វាយរៀង និងខេត្តសៀមរាប។ ការរៀបចំទាំងនេះគឺត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ដែលទទួលបានបទពិសោធន៍ពីបណ្តាប្រទេសនានា ដើម្បីគ្រាន់តែជាការសាកល្បងប៉ុណ្ណោះ ប៉ុន្តែពុំមានគោលការណ៍ជាក់លាក់ឡើយ។ បន្ទាប់ពីរាជរដ្ឋាភិបាលបានប្រកាសធ្វើការកែទម្រង់វិស័យជលផលនៅចុងឆ្នាំ ២000 មក ការរៀបចំសហគមន៍នេសាទបានប្រព្រឹត្តទៅយ៉ាងទូលំទូលាយនៅទូទាំងប្រទេស ក្រោមបន្ទាត់នយោបាយរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានរៀបចំជាបន្តបន្ទាប់នូវលិខិតបទដ្ឋាននានា ដើម្បីជាមូលដ្ឋានបង្អែកក្នុងការរៀបចំ និងគ្រប់គ្រងសហគមន៍នេសាទឱ្យបានសមស្រប។

សៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងសហគមន៍នេសាទនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីៈ

- ផ្តល់ភាពងាយស្រួលដល់អ្នកពាក់ព័ន្ធដែលបំពេញភារកិច្ចនៅក្នុងការងារផ្សព្វផ្សាយ ការងារសម្របសម្រួល ការរៀបចំ និងគ្រប់គ្រងសហគមន៍នេសាទ និងការបំពេញបែបបទនានាដែលជួយដល់សហគមន៍ឈានទៅចុះបញ្ជីជាផ្លូវការឱ្យបានត្រឹមត្រូវ
- បម្រើគុណប្រយោជន៍ចំពោះអ្នកដែលមានបំណងចង់ធ្វើការសិក្សាស្វែងយល់អំពីលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងសហគមន៍នេសាទនៅកម្ពុជា ជាពិសេសចំពោះគ្រូ និស្សិត និងសិស្ស ដែលប្រើប្រាស់សៀវភៅនេះជាឯកសារយោងនៅក្នុងការបង្ហាត់បង្រៀន និងសិក្សារៀនសូត្រមុខវិជ្ជាពាក់ព័ន្ធនានា
- ទុកជាឯកសារយោង និងការប្រើប្រាស់ជាផ្លូវការក្នុងការបំពេញភារកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធទាំងអស់។

សៀវភៅនេះប្រមូលផ្តុំនូវបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ក្នុងនោះមានៈ បទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីជលផល ព្រះរាជក្រឹត្យលេខ នស/រកត/0៥0៥/២៤0 ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២00៥ ស្តីពីការបង្កើតសហគមន៍នេសាទ អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២0 ខែ មីនា ឆ្នាំ ២00៧ និងប្រកាស លេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២00៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។

លិខិតបទដ្ឋានគតិយុត្តិដែលបានរៀបរាប់ខាងលើនេះគឺមានការទាក់ទង និងភាពប្រទាក់ក្រឡាគ្នាពីលិខិតបទដ្ឋានគតិយុត្តិមួយ ទៅលិខិតបទដ្ឋានគតិយុត្តិមួយទៀត។ ខ្លឹមសារសង្ខេបនៃលិខិតបទដ្ឋានដែលមានចែងនៅក្នុងសៀវភៅនេះ មានដូចតទៅៈ

ច្បាប់ស្តីពីជលផលត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦។ នៅក្នុងជំពូកទី ១១ គឺចែងអំពីសហគមន៍នេសាទ រួមមាន ៥ មាត្រា គឺចាប់ពីមាត្រា ៥៩ ដល់មាត្រា ៦៣។ ក្នុងមាត្រា ៥៩ កថាខ័ណ្ឌទី ២ បានបញ្ញត្តិថា " វិធានដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទត្រូវកំណត់ដោយអនុក្រឹត្យ "។ ដោយឡែកនៅក្នុងមាត្រា ៦២ កថាខ័ណ្ឌទី ៤ វិញ បានបញ្ញត្តិ ថា "គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ។ ដូច្នេះការរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ត្រូវបានធ្វើឡើងស្របតាមការចង្អុលបង្ហាញរបស់ច្បាប់ស្តីពីជលផលនេះ។

ដោយឡែកនៅក្នុងការងារចាំបាច់ចំពោះមុខ មុនពេលមានច្បាប់ស្តីពីជលផល រាជរដ្ឋាភិបាលបានរៀបចំព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាដាក់ឱ្យប្រើប្រាស់ ជាផ្លូវការនៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥។ ព្រះរាជក្រឹត្យនេះមាន ៥ មាត្រា ហើយបានចែងអំពីខ្លឹមសារៈសំខាន់ៗពាក់ព័ន្ធនឹងការបង្កើតសហគមន៍នេសាទដូចជា ការផ្តល់នូវសិទ្ធិឱ្យប្រជាពលរដ្ឋចូលរួមដោយស្ម័គ្រចិត្តក្នុងការបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ការកំណត់ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ និងការបង្កើតជាសហព័ន្ធសហគមន៍នេសាទជាដើម ។ បច្ចុប្បន្ននេះ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទក៏នៅជាធរមានដដែល ទោះបីជាច្បាប់ស្តីពីជលផលពុំបានចង្អុលបង្ហាញ អំពីការបង្កើតព្រះរាជក្រឹត្យនេះក៏ដោយ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានធ្វើការកែសម្រួលឱ្យស្របតាមច្បាប់ស្តីពីជលផល។ ដូច្នេះអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទដែលបានរៀបចំមុនពេលដែលច្បាប់ស្តីពីជលផលចូលជាធរមាន គឺត្រូវបានទុកជានិរាករណ៍ចាប់តាំពីថ្ងៃដែលអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទថ្មី លេខ ២៥ អនក្រ ចូលជាធរមាន នៅថ្ងៃ ទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧។ អនុក្រឹត្យលេខ ២៥ អនក្រ. ស្តីពីការគ្រប់គ្រងសហគមន៍នេសាទនេះ រួមមាន ៣៣ មាត្រា ចែកចេញជា ១០ ជំពូក ដែលចែងអំពីវិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ មាន ៣៨ ប្រការ ចែកជា ១៤ ជំពូក។ ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទនេះ មានគោលបំណងដើម្បីពន្យល់អំពីវិធាន និងនីតិវិធីលំអិតក្នុងការបង្កើត និងគ្រប់គ្រងសហគមន៍នេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានចែងអំពីជំហាន និង

ដំណើរការជាបន្តបន្ទាប់ចាប់តាំងពីការផ្តួចផ្តើមគំនិតនៃការរៀបចំ រហូតដល់ការចុះបញ្ជីសហគមន៍នេសាទនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ជាមួយគ្នានេះ មានឯកសារឧបសម្ព័ន្ធចំនួន ៤ ដែលភ្ជាប់ជាមួយប្រកាសនេះគឺ គំរូលក្ខន្តិកៈសហគមន៍នេសាទ គំរូបទបញ្ជាផ្ទៃក្នុង គំរូកិច្ចព្រមព្រៀង និងគំរូផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ដើម្បីអនុវត្តការងាររៀបចំ និងគ្រប់គ្រងសហគមន៍នេសាទឱ្យបានសមស្រប គប្បីសិក្សាលិខិតបទដ្ឋានគតិយុត្តិដែលមានចែងនៅក្នុងសៀវភៅនេះឱ្យបានច្បាស់ ។ ចំពោះអ្នកពាក់ព័ន្ធនីមួយៗ គួរស្វែងយល់ឱ្យបានច្បាស់អំពីតួនាទីភារកិច្ច និងសិទ្ធិរបស់ខ្លួនស្របតាមខ្លឹមសារដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តិទាំងនេះ ។ លើសពីនេះទៅទៀត ការប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តិទាំងនេះសម្រាប់អនុវត្តការងារពាក់ព័ន្ធនឹងការរៀបចំ និងការគ្រប់គ្រងសហគមន៍នេសាទ ត្រូវពិភាក្សា និងសហការជាមួយមន្ត្រីជំនាញ ដើម្បីជៀសវាងការងារខុសឆ្គងនានាដែលអាចកើតមានឡើង ។

ខ្លឹមសារលំអិតនៃលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងសហគមន៍នេសាទដែលបានរៀបរាប់ខាងលើមានចែងជាបន្តបន្ទាប់នៅក្នុងផ្នែកនីមួយៗដូចតទៅៈ

**ផ្នែកទី ១** : ជំពូកទី ១១ នៃច្បាប់ស្តីពីជលផល

**ផ្នែកទី ២** : ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ

**ផ្នែកទី ៣** : អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

**ផ្នែកទី ៤** : ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ និងឧបសម្ព័ន្ធចំនួន ៤ រួមមានៈ

- គំរូលក្ខន្តិកៈសហគមន៍នេសាទ
- គំរូបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- គំរូកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និង
- គំរូផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

# ផ្នែកទី ១

## ច្បាប់ស្ដីពីជលផល

## ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ

## ជំពូកទី ១១
## សហគមន៍នេសាទ

**មាត្រា ៥៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ។

វិធានដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦០.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃដែននេសាទឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬ ក្បែរដែននេសាទក្រោមរូបភាពជាកន្លែងនេសាទសហគមន៍ ។

**មាត្រា ៦១.-**

ខណ្ឌរដ្ឋបាលជលផល តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀតមានភារកិច្ចសិក្សារៀបចំដែននេសាទដើម្បីបង្កើតជាកន្លែងនេសាទសហគមន៍ ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានទំហំសមស្របផ្អែកតាមលទ្ធភាពធនធានជលផល និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ។

នាយខណ្ឌរដ្ឋបាលជលផល មានសិទ្ធិសម្រេចចុះ ឬលុបកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬ ក្បែរដែននេសាទ។ កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលបី ៣) ឆ្នាំ តែអាចពន្យារបាន ដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលជលផល ។

**មាត្រា ៦២.-**

កន្លែងនេសាទសហគមន៍ត្រូវបានគ្រប់គ្រងដោយធានានិរន្តរភាពដោយសហគមន៍នេសាទស្របតាមផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ វិធានសហគមន៍នេសាទ និង គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ។ រដ្ឋបាលជលផលត្រូវផ្តល់ជំនួយបច្ចេកទេស តាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់

ព្រមពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្ដាល ហើយនិងត្រូវពិនិត្យឡើងវិញ ជារៀងរាល់បី (៣) ឆ្នាំម្ដង ឬ មុនពេលកំណត់ក្នុងករណីចាំបាច់ ។

សហគមន៍នេសាទគ្មានសិទ្ធិលក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬ ធ្វើការផ្ទេរកន្លែងនេសាទ សហគមន៍បានឡើយ ។

គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិរំសាយកន្លែងនេសាទសហគមន៍តាមការចាំបាច់ណាមួយសម្រាប់ផលប្រយោជន៍សាធារណៈ ។

# ផ្នែកទី ២

## ព្រះរាជក្រឹត្យស្ដីពីការបង្កើតសហគមន៍នេសាទ

ស/រកត/០៥០៥/២៤០

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតសហគមន៍នេសាទ

៣❖៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

### មាត្រា ១.

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ខ្លួន តាមរយៈការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ។

**មាត្រា ២.**

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៣.**

សហគមន៍នេសាទដែលមានដែននេសាទជាប់គ្នា អាចចូលរួមជាមួយគ្នាដោយបង្កើតជាសហព័ន្ធសហគមន៍នេសាទបាន ។

វិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ . ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកត.០៥០៥.២៥៥

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**

**ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ៣១៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាខ តាន់**

# ផ្នែកទី ៣

## អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**..២៥..អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសហគមន៍នេសាទ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០០ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ០៦ អនក្រ.បក លេខ ០៧ អនក្រ.បក លេខ ០៨ អនក្រ.បក លេខ ០៩ អនក្រ.បក លេខ ១០ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ១៩

អនក្រ.បក លេខ ២១ អនក្រ.បក លេខ ២២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១ និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃ ទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការលុបនាទីឡូត៍នេសាទ និងការកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ក្នុងខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម រាជធានីភ្នំពេញ ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តតាកែវ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.

អនុក្រឹត្យនេះមានវិសាលភាព និងគោលដៅកំណត់អំពីវិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២.

អនុក្រឹត្យនេះមានគោលបំណង ÷

- គ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សា ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបម្រុងទំនាបលិចទឹក ក្នុងរដូវជំនោរឡើង នាទីព្រៃលិចទឹក និងព្រៃកោងកាង និងកន្លែងនេសាទតាមឆ្នេរ
- គ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ពីធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹង និងទទួលស្គាល់កាន់តែច្បាស់ឡើងនូវផលប្រយោជន៍ និងសារៈសំខាន់នៃធនធានជលផលតាមរយៈការចូលរួមគ្រប់គ្រង ប្រើប្រាស់ និងការពារធនធានជលផលដោយផ្ទាល់
- ផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់បង្កភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋខ្មែរនៅតាមមូលដ្ឋានក្នុងការបង្កើតសហគមន៍នេសាទ
- លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

**មាត្រា ៣.**

កន្លែងនេសាទសហគមន៍គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ៤.**

សិទ្ធិអំណាចដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទបានមកពីការបោះឆ្នោតរបស់សមាជិកសហគមន៍។

**មាត្រា ៥.**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់សម្រាប់អនុក្រឹត្យនេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី ២
## ការបង្កើតសហគមន៍នេសាទ

**មាត្រា ៦.**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោល ការណ៍ស្ម័គ្រចិត្តដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។

សហគមន៍នេសាទដែលចែងក្នុងអនុក្រឹត្យនេះ ជារូបវន្តបុគ្គលមួយក្រុមមានសញ្ជាតិខ្មែរ រស់នៅក្នុង ឬក្បែរដែននេសាទ ដែលមានគំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្តបង្កើតឡើង ដើម្បីបង្កើនជីវភាពរស់នៅរបស់ខ្លួនតាមរយៈការប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកបដោយនិរន្តរភាព សំដៅរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។

រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរួមសហការរៀបចំបង្កើតសហគមន៍នេសាទ។

**មាត្រា ៧.**

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា ៨.**

លក្ខន្តិកៈសហគមន៍នេសាទត្រូវបញ្ជាក់ពីចំណុចសំខាន់ៗដូចតទៅ ÷

- នាមករណ៍
- ទីស្នាក់ការ និងអាសយដ្ឋាន
- កម្មវត្ថុ
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- កាតព្វកិច្ច និងសិទ្ធិរបស់សមាជិក
- លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្ដេញចេញនៃសមាជិក
- របៀបរបបនៃការកាន់បញ្ជី និងឯកសារនានា
- សមាសភាពនៃគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការកោះប្រជុំមហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការបែងចែកផលប្រយោជន៍ កម្រៃពីការធ្វើសេដ្ឋកិច្ចសមូហភាព បើសិនជាមាន
- លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ
- នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៣
## តួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍នេសាទ

**មាត្រា ៩.**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងចូលជាសមាជិកសហគមន៍នេសាទ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- មានលំនៅដ្ឋាននៅក្នុងបណ្ដាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង។ បុគ្គលម្នាក់អាចជាសមាជិកសហគមន៍នេសាទតែ មួយគត់នៃសហគមន៍ដែលខ្លួនរស់នៅ។

**មាត្រា ១០.**

តួនាទី និងភារកិច្ចរបស់សហគមន៍នេសាទ ÷

- ចូលរួមគ្រប់គ្រង អភិរក្សធនធានជលផលស្របតាមលក្ខន្តិកៈ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ស្រប តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល
- គោរពតាមការណែនាំរបស់រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ចូលរួមបង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ថែរក្សាការពារ និងដាំដុះព្រៃលិចទឹក និងព្រៃកោងកាង ស្តារព្រែក បឹងដែលរីងរាក់ដើម្បីកែលំអប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានជលផលឡើងវិញ
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍នេសាទមានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពដូចមានចែងក្នុងលក្ខន្តិកៈ
- អនុវត្តលក្ខន្តិកៈសហគមន៍នេសាទ និងធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផល ដើម្បីគ្រប់គ្រងធនធានជលផល ប្រកបដោយនិរន្តរភាព
- រក្សាទុកឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**មាត្រា ១១.**

សិទ្ធិរបស់សហគមន៍នេសាទ ÷

- ចាត់ចែងការធ្វើនេសាទរបស់សមាជិកទាំងអស់ឱ្យបានសមស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ
- សហការជាមួយរដ្ឋបាលជលផលដើម្បីបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍។ ក្នុងករណីបន្ទាន់ និងចាំបាច់សហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាង ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសរួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយបទល្មើសតាមលក្ខណៈច្បាប់
- ធ្វើទំនាក់ទំនងជាមួយសហគមន៍នេសាទនានា រូបវន្តបុគ្គល ឬនីតិបុគ្គលនានា ដើម្បីផលប្រយោជន៍របស់សហគមន៍ នេសាទស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន
- ធ្វើនេសាទ ធ្វើវារីវប្បកម្ម ប្រមូលផល លក់ ប្រើប្រាស់ និងគ្រប់គ្រងរាល់ធនធានជលផលស្របតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

**មាត្រា ១២.**

សហគមន៍នេសាទពុំមានសិទ្ធិ ÷

- លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ខ្ចី បញ្ចាំ ឬផ្ទេរកន្លែងនេសាទសហគមន៍បានឡើយ ទោះតាមរូបភាពណាក៏ដោយ
- ធ្វើទំនប់ ឬធ្វើនេសាទដែលបណ្ដាលឱ្យរាំងស្ទះមុខព្រែក អូរ ប្រឡាយ ឬចរាចរត្រី។ ករណីនេះអាចធ្វើបានលុះត្រាតែមានការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់រដ្ឋបាលជលផលថ្នាក់កណ្ដាលក្រោយពីបានពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ
- បែងចែកធ្វើជាកម្មសិទ្ធិឯកជននូវដីព្រៃលិចទឹក និងព្រៃកោងកាង ដីលិចទឹកព្រមទាំងកន្លែងនេសាទនៅក្នុងកន្លែង នេសាទសហគមន៍ដែលផ្ដល់ឱ្យសហគមន៍នេសាទគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចុះកិច្ចព្រមព្រៀងផ្សេងៗដែលពាក់ព័ន្ធក្នុងកន្លែងនេសាទសហគមន៍ជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលនានា ទោះបីក្នុងករណីស្រាវជ្រាវវិទ្យាសាស្ត្រក៏ដោយ ។

**មាត្រា ១៣.**

សមាជិកសហគមន៍នេសាទមានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះបោះឆ្នោតក្នុងរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី( ១/៣) នៃសមាជិកទាំងអស់
- លើកសំណូមពរឱ្យដាក់ចូលរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាទាំងឡាយណាដែលមានប្រយោជន៍សម្រាប់សហគមន៍នេសាទ
- ធ្វើនេសាទជាលក្ខណៈគ្រួសារតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យជលផល និងលក្ខន្តិកៈសហគមន៍នេសាទ
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្ដឹងតវ៉ា ឬផ្ដល់ព័ត៌មានអំពីបាតុភាពទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ ។

ក្នុងករណីមានសមាជិកណាម្នាក់នៃសហគមន៍នេសាទណាមួយ រារាំងមិនឱ្យសមាជិកដទៃទៀតក្នុងសហគមន៍នេសាទ ដែលខ្លួនជាសមាជិកអនុវត្តសិទ្ធិដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ឬធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់

ផលប្រយោជន៍សហគមន៍ ឬសមាជិកសហគមន៍នេសាទដទៃទៀត សមាជិករូបនោះអាចត្រូវព្យួរ ឬបណ្តេញចេញពីសហគមន៍ ក្រោយពីបានការពារខ្លួនចំពោះមុខគណៈកម្មការសហគមន៍នេសាទ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរៀងៗខ្លួន និងរួមគ្នាផងចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកថ្មីដែលសុំចូលជាសមាជិកសហគមន៍នេសាទ ត្រូវបញ្ជាក់អំពីការសុខចិត្តគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ព្រមទាំងសេចក្តីសម្រេចនានារបស់មហាសន្និបាតសហគមន៍នេសាទ ។

## មាត្រា ១៤.

អ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទអាចមានសិទ្ធិចេញ ចូល និងប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ដោយត្រូវអនុវត្តឱ្យស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។

# ជំពូកទី ៤
# គណៈកម្មការសហគមន៍នេសាទ

## មាត្រា ១៥.

សហគមន៍នេសាទនីមួយៗត្រូវដឹកនាំដោយគណៈកម្មការមួយហៅថា "**គណៈកម្មការសហគមន៍នេសាទ**" ។ គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតរបស់មហាសន្និបាតដោយសម្ងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រភាគច្រើនដាច់ខាតពីសមាជិកសហគមន៍នេសាទដែលបានចូលរួម ។

## មាត្រា ១៦.

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសំឡេងឆ្នោតបន្ទាប់គឺជាអនុប្រធានគណៈកម្មការសហគមន៍នេសាទ ។

រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតការណ៍ ឬសម្របសម្រួលក្នុងការបោះឆ្នោត ។ លទ្ធផលនៃការបោះឆ្នោតត្រូវបានទទួលស្គាល់ជាផ្លូវការ ទោះបីអវត្តមាន នៃរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ឬក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដោយ ។

**មាត្រា ១៧.**

សមាជិកគណៈកម្មការសហគមន៍នេសាទមានចំនួនសេសពីប្រាំ(៥)រូប ទៅដប់មួយ(១១)រូប អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង និងសេចក្តីសម្រេចរបស់មហាសន្និបាត ដោយត្រូវលើកទឹកចិត្តឱ្យមានស្ត្រីភេទចូលរួមឈរឈ្មោះជា បេក្ខជនក្នុងគណៈកម្មការសហគមន៍នេសាទ ។

**មាត្រា ១៨.**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានសិទ្ធិ និងបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសជាគណៈកម្មការសហគមន៍នេសាទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- ជាសមាជិកនៃសហគមន៍នេសាទសាមី
- មានសញ្ជាតិខ្មែរពីកំណើត ។

**មាត្រា ១៩.**

គណៈកម្មការសហគមន៍នេសាទទទួលសិទ្ធិអំណាចក្នុងកិច្ចការដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទស្របតាមមាត្រា ១១ និងមាត្រា ១២ នៃអនុក្រឹត្យនេះ ។ គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥) ឆ្នាំ ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**មាត្រា ២០.**

គណៈកម្មការសហគមន៍នេសាទមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- រៀបចំសេចក្តីព្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រតិបត្តិស្របតាមលក្ខខណ្ឌនៅក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីរដ្ឋបាលជលផល ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយផ្សេងៗក្នុងការអនុវត្តដំណើរការសហគមន៍នេសាទ
- តំណាងឱ្យសហគមន៍នេសាទក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន
- បើកគណនី និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍នេសាទ ដោយមានតម្លាភាព និងការទទួលខុសត្រូវ
- ធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍសហគមន៍នេសាទ ដោយមានការយល់ព្រមពីសមាជិកសហគមន៍នេសាទភាគច្រើនស្របទៅតាមលក្ខន្តិកៈសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការ

គ្រប់គ្រង កន្លែងនេសាទសហគមន៍

- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ញានានាដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់សហគមន៍នេសាទ
- រាយការណ៍ និងផ្តល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ដល់រដ្ឋបាលជលផលដែលនៅជិតបំផុត
- ធ្វើការអភិរក្ស និងការពារវារិជាតនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តតួនាទីចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋបាលជលផល
- ធ្វើការតវ៉ាចំពោះការមិនបន្តកិច្ចព្រមព្រៀងឱ្យសហគមន៍នេសាទ។

**មាត្រា ២១.**

មានតែគណៈកម្មការសហគមន៍នេសាទទេ ដែលមានសិទ្ធិដាក់ពាក្យស្នើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ទៅខណ្ឌរដ្ឋបាលជលផលដើម្បីសុំការឯកភាព។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផល ឬអ្នកដែលមានជំនាញក្នុងការគ្រប់គ្រងសហគមន៍នេសាទ ដើម្បីធ្វើការរៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៥
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា ២២.**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ធ្វើជាអាណាព្យាបាលរបស់សហគមន៍នេសាទ
- ចេញប្រកាសទទួលស្គាល់ បដិសេធ ឬរំសាយសហគមន៍នេសាទ
- ចេញប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ និងភ្ជាប់ជាមួយនូវគំរូលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ សហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយស្ថាប័ន អាជ្ញាធរ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធ
- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតលើការអនុវត្ត និងការអភិវឌ្ឍក្នុងការគ្រប់គ្រងសហគមន៍នេសាទ
- ធ្វើអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់របស់សហគមន៍នេសាទ
- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ។

**មាត្រា ២៣.**

រដ្ឋបាលជលផលថ្នាក់កណ្តាល មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះបញ្ជីទទួលស្គាល់ ឬរំសាយសហគមន៍នេសាទចេញពីបញ្ជី ក្នុងករណីពិនិត្យឃើញថាសហគមន៍នេសាទមិនគោរពតាមខ្លឹមសារនៃកិច្ចព្រមព្រៀង
- ពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិនិត្យ និងដោះស្រាយរាល់សំណើរបស់សហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព
- ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍
- ដោះស្រាយទំនាស់វិស័យជលផលក្នុងកន្លែងនេសាទសហគមន៍
- សម្របសម្រួលក្នុងការរៀបចំសហគមន៍នេសាទ កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ លក្ខន្តិកៈសហគមន៍នេសាទ ផែនការគ្រប់គ្រងសហគមន៍នេសាទ និងការធ្វើសកម្មភាពគ្រប់គ្រងធនធានជលផលរបស់សហគមន៍នេសាទ
- ផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល និងឯកសារដែលទាក់ទងនឹងសហគមន៍នេសាទ
- អប់រំ បណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសជំនាញសម្រាប់ការគ្រប់គ្រងដល់សហគមន៍នេសាទ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់សហគមន៍នេសាទ និងធ្វើរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ។

## ជំពូកទី ៦

## កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

**មាត្រា ២៤.**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវភ្ជាប់មកជាមួយ ÷

- ផែនទីមាត្រដ្ឋាន ១/៥០.០០០ បញ្ជាក់ពីតំបន់ស្នើសុំបង្កើតកន្លែងនេសាទសហគមន៍ដែលមាននិយាមកាច្បាស់លាស់
- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ

- សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងនៃការបង្កើតសហគមន៍នេសាទ និងការគ្រប់គ្រងធនធានជលផល ដោយមាន ការអះអាងអំពីការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព
- ឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់។

## មាត្រា ២៥.

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវប្រកាសជូនដំណឹងដោយបិទផ្សាយយ៉ាងតិចសាមសិប(៣០)ថ្ងៃ នៅតាមកន្លែងសាធារណៈនានាដែលងាយមើលឃើញនៅសាលាឃុំ សង្កាត់ ស្រុក ខណ្ឌ និងខេត្ត ក្រុង មុននឹងដាក់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជូនខណ្ឌរដ្ឋបាលជលផលដើម្បីពិនិត្យ និងចុះកិច្ចព្រមព្រៀង។

ក្នុងករណីមានការជំទាស់កើតឡើងក្នុងអំឡុងពេលប្រកាសជូនដំណឹង ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរស្រុក ខណ្ឌ និងខេត្ត ក្រុង ត្រូវជួយសម្របសម្រួលដល់គណៈកម្មការសហគមន៍នេសាទដើម្បីដោះស្រាយទំនាស់ ឬកែសម្រួលសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ តាមការស្នើឡើងដោយគណៈកម្មការសហគមន៍នេសាទ។

នីតិវិធីនៃការរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា ២៦.

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ មានសុពលភាពមិនលើសពីរយៈពេលបី(៣)ឆ្នាំ ចាប់ពីថ្ងៃឯកភាពដោយខណ្ឌរដ្ឋបាលជលផល។

គណៈកម្មការសហគមន៍នេសាទ ត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ខណ្ឌរដ្ឋបាលជលផលរយៈពេលប្រាំមួយ(៦)ខែ មុនពេលកិច្ចព្រមព្រៀងផុតសុពលភាព ដើម្បីបន្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាថ្មី។

ការសុំបន្តនេះ ត្រូវបានអនុញ្ញាតជូនតាមរយៈសេចក្តីជូនដំណឹងរបស់ខណ្ឌរដ្ឋបាលជលផល ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ មុនថ្ងៃផុតកំណត់នៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ ខណ្ឌរដ្ឋបាលជលផលបញ្ចប់កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ឬមិនផ្តល់ការអនុញ្ញាតឱ្យបន្តប្រសិនបើខណ្ឌរដ្ឋបាលជលផល បានធ្វើជូនគណៈកម្មការសហគមន៍នេសាទ នូវរបាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យ និងវាយតម្លៃរបស់ថ្នាក់ផ្នែករដ្ឋបាលជលផលសាមី ដែលមានការចូលរួមជាមួយគណៈកម្មការសហគមន៍នេសាទលើដំណើរការអនុវត្តការគ្រប់គ្រងកន្លែងនេសាទសហគមន៍កន្លងមក ដោយបញ្ជាក់នូវមូលហេតុ និងភស្តុតាងនៃការមិនគោរពកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ក្នុងករណីដែលខណ្ឌរដ្ឋបាលជលផល មិនបានផ្តល់សេចក្តីជូនដំណឹងចំពោះការស្នើសុំបន្តកិច្ចព្រមព្រៀង

កន្លែងនេសាទសហគមន៍ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ មុនថ្ងៃផុតសុពលភាព កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវបានបន្តដោយស្វ័យប្រវត្តិ។

**មាត្រា ២៧.**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចបញ្ឈប់មុនពេលកំណត់ ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចខាងក្រោម÷

១- ការឯកភាពគ្នារវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ។

២- ការព្រមព្រៀងគ្នាក្នុងគណៈកម្មការសហគមន៍នេសាទ និងមានការឯកភាពពីរភាគបី(២/៣) ពីសមាជិកសហគមន៍នេសាទ។

៣- ការមិនអនុវត្ត ឬអនុវត្តរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងបទប្បញ្ញត្តិនានា ដែលមិនធានានិរន្តរភាពធនធានជលផល។

៤-ការយល់ឃើញរបស់រាជរដ្ឋាភិបាលនូវគោលបំណងផ្សេងមួយទៀតដែលផ្តល់ផលប្រយោជន៍សាធារណៈ និងសង្គមចំពោះព្រះរាជាណាចក្រកម្ពុជាច្រើនជាង។

ក្នុងករណីដូចចំណុចទី ៤ នៃមាត្រា ២៧ នៃអនុក្រឹត្យនេះ ខណ្ឌរដ្ឋបាលជលផលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំមួយ(៦)ខែ មុនការបញ្ឈប់ទៅឱ្យគណៈកម្មការសហគមន៍នេសាទ ដោយបញ្ជាក់ប្រាប់ពីមូលហេតុនៃការបញ្ឈប់នោះ។ ក្នុងរយៈពេលនេះ ខណ្ឌរដ្ឋបាលជលផលត្រូវធ្វើការពិភាក្សាសម្របសម្រួលជាមួយគណៈកម្មការសហគមន៍នេសាទចំពោះការបាត់បង់ផលប្រយោជន៍របស់សហគមន៍។

## ជំពូកទី ៧
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**មាត្រា ២៨.**

បន្ទាប់ពីមានការឯកភាពលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ពីរដ្ឋបាលជលផល។

គណៈកម្មការសហគមន៍នេសាទត្រូវដាក់ស្នើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជូនទៅរដ្ឋបាល

ជលផលថ្នាក់កណ្តាលតាមរយៈខណ្ឌរដ្ឋបាលជលផលសាមីដើម្បីធ្វើការពិនិត្យ និងសម្រេច ។

វិធាននៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

**មាត្រា ២៩.**

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានពិនិត្យឡើងវិញដោយខណ្ឌរដ្ឋបាលជលផលរៀងរាល់ឆ្នាំ ឬមុនរយៈពេលនេះប្រសិនបើចាំបាច់ ដើម្បីរាយការណ៍ជូនរដ្ឋបាលជលផលថ្នាក់កណ្តាល ។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានការចូលរួមពីតំណាងគណៈកម្មការសហគមន៍នេសាទ ។

រដ្ឋបាលជលផលថ្នាក់កណ្តាលអាចតម្រូវឱ្យគណៈកម្មការសហគមន៍នេសាទ ធ្វើការកែសម្រួលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឡើងវិញស្របទៅតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធានាដល់និរន្តរភាពនៃកន្លែងនេសាទសហគមន៍ ។

## ជំពូកទី ៨
## ប្រភពហិរញ្ញវត្ថុ

**មាត្រា ៣០.**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៣១.**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៣២.**

អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធត្រូវអនុវត្ត អនុក្រឹត្យ នេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ [illegible] ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចាន់.សារុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..២៥.. អនក្រ ចុះថ្ងៃទី..២០..ខែ..មិនា..ឆ្នាំ ២០០៧

## ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

**កន្លែងនេសាទសហគមន៍** : សំដៅដល់ដែននេសាទរបស់រដ្ឋដែលបានព្រមព្រៀងផ្តល់សិទ្ធិជូនសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុង ឬក្បែរដែននេសាទដើម្បីប្រើប្រាស់ជាប្រពៃណី ។

**ការប្រើប្រាស់ប្រកបដោយនិរន្តរភាព** : សំដៅដល់ការប្រើប្រាស់ធនធានជលផលដោយធានារក្សានូវប្រភពធនធានជលផលនោះឱ្យបានគង់វង្សសម្រាប់ជាផលប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់ ។

**កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍** : សំដៅដល់ការព្រមព្រៀងមួយជាលាយលក្ខណ៍អក្សររវាងសហគមន៍នេសាទ និងខណ្ឌរដ្ឋបាលជលផលដែលបានផ្តល់និងធានាសិទ្ធិរបស់សហគមន៍នេសាទក្នុងកន្លែងនេសាទជាក់លាក់ណាមួយ ។

**ជំនួយ** : សំដៅដល់អំណោយ ឬកម្ចី ។

**ទ្រព្យសម្បត្តិសាធារណៈ** : សំដៅដល់ទ្រព្យដែលត្រូវរក្សាឱ្យគង់រូបតាមធម្មជាតិរបស់វា ដើម្បីទុកឱ្យអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅ ។ ទ្រព្យទាំងនេះស្ថិតនៅជាប្រយោជន៍សាធារណៈមិនអាចលក់ដូរ និងគ្មានកំណត់អាជ្ញាយុកាលទេ ។

**បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ** : សំដៅដល់លក្ខខណ្ឌដែលបានអនុម័តដោយមហាសន្និបាតសហគមន៍នេសាទ ស្តីពីការប្រតិបត្តិផ្ទៃក្នុងរបស់សហគមន៍នេសាទ ។

**ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** : សំដៅដល់ឯកសារដែលបានរៀបចំឡើងដោយសហគមន៍នេសាទ និងមានការឯកភាពពីរដ្ឋបាលជលផលថ្នាក់កណ្តាលដោយមានការវាយតម្លៃហេតុប៉ះពាល់សង្គម បរិស្ថាន និងបញ្ជាក់លំអិតអំពីនីតិវិធីបទបញ្ជា និងវិធានការពាក់ព័ន្ធនឹងការរៀបចំប្រើប្រាស់កន្លែងនេសាទសហគមន៍ប្រកបដោយនិរន្តភាព ។

**លក្ខន្តិកៈសហគមន៍នេសាទ** : សំដៅដល់ "សេចក្តីកំណត់ដាច់ស្រេច" ដែលបានអនុម័តដោយមហាសន្និបាតសហគមន៍នេសាទ ស្របតាមគំរូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**សហគមន៍នេសាទ** : សំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានយល់ព្រមសហការគ្នាចូលរួមគ្នាដោយស្ម័គ្រចិត្តក្នុងគោលបំណងចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ ប្រើប្រាស់ធនធានជលផលនៅតាមមូលដ្ឋានប្រកបដោយនិរន្តរភាព និងការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។

# ផ្នែកទី ៤

## ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ

**ឧបសម្ព័ន្ធ:**

- គំរូលក្ខន្តិកៈសហគមន៍នេសាទ
- គំរូបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- គំរូកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- គំរូផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ៣១៦ ប្រក.កសក

# ប្រកាស
# ស្តីពី
# គោលការណ៍ណែនាំអំពីសហគមន៍នេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- តាមសំណើរបស់រដ្ឋបាលជលផល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះកំណត់នូវគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ដោយមានគោលបំណងដើម្បីពន្យល់អំពីវិធាន និងនីតិវិធីជាមូលដ្ឋានក្នុងការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយកំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល ។

## ជំពូកទី ២

## ការបង្កើត និងភារកិច្ចរបស់ក្រុមស្ថាបនិក

**ប្រការ ២.-**

សហគមន៍មូលដ្ឋានដែលមានបំណងបង្កើតសហគមន៍នេសាទ ត្រូវបង្កើតក្រុមស្ថាបនិករបស់ខ្លួន ដោយជ្រើសរើសចេញពីបណ្តាប្រជាពលរដ្ឋក្នុងតំបន់ដែលខ្លួនស្នាក់នៅ ហើយត្រូវពិនិត្យអំពីលក្ខណៈសម្បត្តិរបស់បុគ្គលនីមួយៗឱ្យបានសមស្របតាមការចង់បានរបស់ប្រជាពលរដ្ឋ ដោយមានការសម្របសម្រួលពីអាជ្ញាធរភូមិ ឃុំ សង្កាត់ រដ្ឋបាលជលផលមូលដ្ឋានសាមី និងសមត្ថកិច្ចពាក់ព័ន្ធ ។

**ប្រការ ៣.-**

សមាជិកក្រុមស្ថាបនិកដែលត្រូវបានជ្រើសរើស ត្រូវដាក់ពាក្យស្នើសុំបង្កើតសហគមន៍នេសាទជាលាយលក្ខណ៍អក្សរមកខណ្ឌរដ្ឋបាលជលផលតាមរយៈមេឃុំ ឬចៅសង្កាត់ សង្កាត់រដ្ឋបាលជលផល និងផ្នែករដ្ឋបាលជលផលដោយ ភ្ជាប់មកជាមួយនូវគំនូសព្រាងផែនទីបណ្តោះអាសន្នអំពីទីតាំងដែលស្នើសុំ ។

**ប្រការ ៤.-**

មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចត្រូវចុះពិនិត្យទីកន្លែងស្នើសុំបង្កើតសហគមន៍នេសាទ ដោយធ្វើការប្រជុំពិភាក្សាប្រមូលព័ត៌មានពីប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ និងសិក្សាវាយតម្លៃអំពីស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងការប្រើប្រាស់ធនធានជលផលឱ្យបានច្បាស់លាស់ ។

ខណ្ឌរដ្ឋបាលជលផលត្រូវជូនដំណឹងទៅសហគមន៍មូលដ្ឋានរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីទទួលពាក្យស្នើសុំ

ដើម្បីបញ្ជាក់ពីការឯកភាព ឬបដិសេធលើសំណើសុំបង្កើតសហគមន៍នេសាទ។

ការមិនឆ្លើយតបតាមរយៈពេលកំណត់ខាងលើ នឹងត្រូវចាត់ទុកជាការឯកភាពតាមសំណើ។

**ប្រការ ៥.—**

រដ្ឋបាលជលផលត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងសមត្ថកិច្ចពាក់ព័ន្ធដែលជាក្រុមអ្នកសម្របសម្រួល មានភារកិច្ចជួយសម្រួលរាល់កិច្ចការរបស់ក្រុមស្ថាបនិក។

**ប្រការ ៦.—**

ក្រុមស្ថាបនិកមានភារកិច្ចរៀបចំកិច្ចការទាំងឡាយរបស់មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ចាប់តាំងពីកិច្ចការត្រៀមរហូតដល់បញ្ចប់ដូចមានចែងខាងក្រោម ÷

- ចុះបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តចូលរួមជាសមាជិកសហគមន៍នេសាទ
- ធ្វើលិខិតអញ្ជើញចូលរួមមហាសន្និបាត
- កំណត់ពេលវេលា របៀបវារៈ និងជ្រើសរើសទីកន្លែងមហាសន្និបាត
- រៀបចំឯកសារទាក់ទងនឹងមហាសន្និបាត
- រៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទដោយមានការពិគ្រោះយោបល់
- រៀបចំត្រៀមបេក្ខភាពគណៈកម្មការរៀបចំការបោះឆ្នោត
- រៀបចំត្រៀមបេក្ខភាពឈរឈ្មោះបោះឆ្នោតជាគណៈកម្មការសហគមន៍នេសាទ ដែលត្រូវបានជ្រើសរើសជាតំណាងប្រជាពលរដ្ឋពីមូលដ្ឋាន
- ត្រៀមឈ្មោះសហគមន៍នេសាទ
- រៀបចំអង្គប្រជុំផ្សេងៗពាក់ព័ន្ធនឹងការត្រៀមធ្វើមហាសន្និបាត
- រៀបចំដំណើរការមហាសន្និបាត។

សមាជិកក្រុមស្ថាបនិកមានសិទ្ធិឈរឈ្មោះជាបេក្ខជន ដែលត្រូវជ្រើសរើសជាគណៈកម្មការសហគមន៍ នេសាទ។

**ប្រការ ៧.—**

សមាជិកក្រុមអ្នកសម្របសម្រួល និងសមាជិកក្រុមស្ថាបនិកត្រូវចាត់ចែងធ្វើការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីសារប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ ដើម្បីឱ្យប្រជាពលរដ្ឋស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ យ៉ាងហោចណាស់លើសពីពាក់កណ្តាលនៃចំនួនគ្រួសារអ្នកនេសាទសរុបនៅកន្លែងនោះ។

ក្នុងករណីដែលចំនួនអ្នកចូលរួមពុំបានចំនួនភាគច្រើនគ្រប់តាមការកំណត់ខាងលើ គឺត្រូវបន្តខិតខំធ្វើការផ្សព្វផ្សាយបន្ថែមទៀត ។

## ជំពូកទី ៣
## លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

### ប្រការ ៨.-

សមាជិកក្រុមអ្នកសម្របសម្រួល និងសមាជិកក្រុមស្ថាបនិកត្រូវរៀបចំធ្វើការប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានលើសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដើម្បីដាក់ជូនមហាសន្និបាតធ្វើការអនុម័ត ។
គំរូលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ១ និង ទី ២ នៃប្រកាសនេះ ។

### ប្រការ ៩.-

លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទដែលបានអនុម័តរួចហើយ អាចស្នើធ្វើការកែសម្រួលបានតាមរយៈមហាសន្និបាត ។

លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ បន្ទាប់ពីបានអនុម័តរួច ។

ឯកសារលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងត្រូវតម្កល់ទុកមួយច្បាប់នៅគណៈកម្មការសហគមន៍នេសាទ មួយច្បាប់នៅសាលាឃុំ សង្កាត់ មួយច្បាប់នៅខណ្ឌរដ្ឋបាលជលផល និងអាចចម្លងជូនអ្នកពាក់ព័ន្ធដោយច្បាប់ចម្លង ។

## ជំពូកទី ៤
## មហាសន្និបាតសហគមន៍នេសាទ

### ប្រការ ១០.-

មហាសន្និបាតសហគមន៍នេសាទគឺជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ ។

មហាសន្និបាតសហគមន៍នេសាទមាន ÷

- មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទដែលរៀបចំដោយក្រុមស្ថាបនិក ប្រារព្ធធ្វើឡើងដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- មហាសន្និបាតសាមញ្ញត្រូវប្រារព្ធធ្វើឡើងក្នុងរយៈពេល ១ ឆ្នាំម្តង
- មហាសន្និបាតវិសាមញ្ញប្រារព្ធធ្វើឡើងតាមការចាំបាច់របស់សហគមន៍នេសាទ ។

**ប្រការ ១១.—**

ការរៀបចំ និងដំណើរការមហាសន្និបាត÷

**ក. ការរៀបចំកន្លែង**

កន្លែងប្រារព្ធធ្វើមហាសន្និបាតត្រូវជ្រើសរើសឱ្យបានសមរម្យនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីធានាឱ្យការប្រព្រឹត្តទៅរបស់មហាសន្និបាតទទួលបានលទ្ធផលល្អ។

**ខ. ដំណើរការមហាសន្និបាត**

ដំណើរការរបស់មហាសន្និបាតរួមមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ÷

- ចុះឈ្មោះអ្នកចូលរួម
- ប្រកាសហេតុបើកមហាសន្និបាត
- ប្រកាសគណៈអធិបតី និងអ្នកចូលរួមមហាសន្និបាត
- គោរពភ្លេងជាតិ
- សុន្ទរកថា ឬមតិបើកមហាសន្និបាត
- ការអនុម័តលេខាកត់ត្រា
- អនុម័តរបៀបវារៈសំខាន់ៗដែលបានត្រៀមរៀបចំ
- ពិភាក្សា និងអនុម័តលើការងារដែលបានចែងនៅក្នុងរបៀបវារៈ
- សរុបលទ្ធផលនៃមហាសន្និបាត
- មតិផ្តាំផ្ញើរបស់គណៈអធិបតី និងបិទកម្មវិធីមហាសន្និបាត ។

**គ. ភារកិច្ចរបស់គណៈអធិបតី**

- ដឹកនាំមហាសន្និបាតទាំងមូល
- ស្នើមហាសន្និបាតអនុម័តកិច្ចការសំខាន់ៗពាក់ព័ន្ធនឹងការប្រព្រឹត្តទៅរបស់មហាសន្និបាត
- ស្នើមហាសន្និបាតអនុម័តកិច្ចការសំខាន់ៗដែលបានពិភាក្សាតាមរបៀបវារៈ ។

## ជំពូកទី ៥

## ការបង្កើតសហគមន៍នេសាទ

**ប្រការ ១២.—**

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ រៀបចំឡើងដើម្បីធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ មានរបៀបវារៈសំខាន់ៗដូចខាងក្រោម ÷

- អនុម័តសមាជិកសហគមន៍នេសាទ

- អនុម័តឈ្មោះសហគមន៍នេសាទ

- អនុម័តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

- ជ្រើសរើស និងអនុម័តគណៈកម្មការរៀបចំការបោះឆ្នោត

- អនុម័តចំនួនគណៈកម្មការសហគមន៍នេសាទ

- អនុម័តចំនួន និងសមាសភាពបេក្ខជនឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទ

- ណែនាំអំពីរបៀបបោះឆ្នោត

- ដំណើរការបោះឆ្នោត

- ប្រកាសលទ្ធផលនៃការបោះឆ្នោត

- ការចាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់តំណាងគណៈកម្មការសហគមន៍នេសាទដែលទើបនឹងជាប់ឆ្នោត។

**ប្រការ ១៣.–**

ភារៈកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតមាន ៖

- ធ្វើការពន្យល់អំពីវិធីសាស្ត្រ នៃការបោះឆ្នោតជូនមហាសន្និបាត

- ចាត់ចែងការបោះឆ្នោតរហូតដល់ចប់

- រាយការណ៍អំពីលទ្ធផលនៃការបោះឆ្នោត និងប្រគល់កម្មវិធី ព្រមទាំងសំណុំលិខិតជូនគណៈអធិបតី។

**ប្រការ ១៤.–**

លក្ខខណ្ឌនៃការជ្រើសរើសគណៈកម្មការសហគមន៍នេសាទត្រូវធ្វើឡើងផ្អែកលើមាត្រា ១៧ និងមាត្រា ១៨ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។ បេក្ខភាពឈរឈ្មោះគណៈកម្មការសហគមន៍នេសាទ ត្រូវមានចំនួនយ៉ាងតិច ៣ នាក់ លើសពីចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលត្រូវជ្រើសរើស។ ក្នុងករណីដែលសហគមន៍នេសាទត្រូវបានបង្កើតឡើងដោយមានភូមិច្រើនចូលរួម បេក្ខភាពឈរឈ្មោះគណៈកម្មការត្រូវជ្រើសរើសឱ្យបានពីគ្រប់ភូមិទាំងនោះ។

អាណត្តិរបស់ក្រុមស្ថាបនិកត្រូវបញ្ចប់ជាស្វ័យប្រវត្ត បន្ទាប់ពីគណៈកម្មការសហគមន៍ថ្មីត្រូវបានជ្រើសតាំងរួច។

**ប្រការ ១៥.–**

នៅមុនពេលផុតអាណត្តិរយៈពេលមួយខែ គណៈកម្មការសហគមន៍នេសាទត្រូវជ្រើសរើសគណៈកម្មការរៀបចំការបោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីត្រៀមរៀបចំមហាសន្និបាតបោះឆ្នោតជ្រើសរើស

គណៈកម្មការសហគមន៍នេសាទអាណត្តិថ្មី ដែលមានដំណើរការដូចមហាសន្និបាតកំណើតដំបូង។

## ជំពូកទី ៦
## ការកំណត់ទីតាំងកន្លែងនេសាទសហគមន៍

**ប្រការ ១៦.–**

ទីតាំងសម្រាប់រៀបចំកន្លែងនេសាទសហគមន៍មានដូចខាងក្រោម ÷

**ក. ដែននេសាទទឹកសាប**

-ផ្ទៃឡូត៍នេសាទដែលត្រូវបានលុប ឬកាត់បន្ថយ

- កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ

- កន្លែងនេសាទបម្រុង

- ទំនាបលិចទឹកក្នុងរដូវជំនន់ឡើង

- នាទីព្រៃលិចទឹក

- អាងទឹក ស្រះ បឹង និងអន្លង់ត្រីមេពូជ ។ល។

**ខ. ដែននេសាទសមុទ្រ**

-កន្លែងនេសាទតាមឆ្នេរ ដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ខ្សែបន្ទាត់ដែលមានជម្រៅទឹក ២០ ម៉ែត្រ

- នាទីព្រៃកោងកាង។

**ប្រការ ១៧.–**

ការកំណត់ព្រំប្រទល់ និងការធ្វើផែនទីកន្លែងនេសាទសហគមន៍ ត្រូវមានការពិគ្រោះយោបល់នៅក្នុងមូលដ្ឋានសហគមន៍នេសាទឱ្យបានច្បាស់លាស់។ គណៈកម្មការកំណត់ព្រំប្រទល់ រៀបចំផែនទីកន្លែងនេសាទ សហគមន៍ និងដោះស្រាយវិវាទត្រូវបង្កើត និងដឹកនាំដោយរដ្ឋបាលជលផលថ្នាក់កណ្តាល ដែលមានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| - ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ឬតំណាង | ជាប្រធាន |
| - នាយខណ្ឌរដ្ឋបាលជលផល | ជាអនុប្រធាន |
| - អភិបាលស្រុកពាក់ព័ន្ធ | ជាអនុប្រធាន |
| - ប្រធាន ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន | ជាសមាជិក |
| - មេភូមិក្នុងសហគមន៍មូលដ្ឋានពាក់ព័ន្ធ | ជាសមាជិក |

- តំណាងគណៈកម្មការសហគមន៍នេសាទ ជាសមាជិក
- តំណាងគណៈកម្មការសហគមន៍នេសាទដែលជាប់នឹងកន្លែងនេសាទសហគមន៍ ជាសមាជិក
- អាជីវករឡូត៍នេសាទដែលជាប់នឹងកន្លែងនេសាទសហគមន៍ ជាសមាជិក
- អ្នកនេសាទចាស់ទុំ ជាសមាជិក

ក្នុងករណីចាំបាច់ អាចអញ្ជើញអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមនៅក្នុងការកំណត់ព្រំប្រទល់នេះ។ ការកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ត្រូវធ្វើកំណត់ហេតុឱ្យបានច្បាស់លាស់ ដោយបញ្ជាក់អំពីទីតាំងបង្គោលដែលមានបញ្ជាក់និយាមកា និងចំណុចគោលដៅទាំងឡាយដែលពាក់ព័ន្ធ។

## ជំពូកទី ៧
## កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

### ប្រការ ១៨.-

ផ្អែកលើគំរូកិច្ចព្រមព្រៀងដែលបានកំណត់លក្ខខណ្ឌអប្បរមា ដូចមានភ្ជាប់ឧបសម្ព័ន្ធទី ៣ នៃប្រកាសនេះ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំ កិច្ចព្រមព្រៀងដែលមានដំណើរការដូចខាងក្រោម ៖

- គណៈកម្មការសហគមន៍នេសាទត្រូវធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានរបស់ខ្លួនឱ្យបានទូលំទូលាយ មុននឹងដាក់ជូនមហាសន្និបាតសហគមន៍នេសាទធ្វើការអនុម័ត
- គណៈកម្មការសហគមន៍នេសាទត្រូវជូនព័ត៌មានមកខណ្ឌរដ្ឋបាលជលផល ដើម្បីចាត់តំណាងចុះត្រួត ពិនិត្យជាក់ស្តែងអំពីភូមិសាស្ត្រ និងឧបករណ៍នេសាទរបស់សហគមន៍
- គណៈកម្មការសហគមន៍នេសាទត្រូវស្នើសុំទៅខណ្ឌរដ្ឋបាលជលផល ដើម្បីចុះកិច្ចព្រមព្រៀងដោយភ្ជាប់នូវឯកសារនានាផ្អែកតាមមាត្រា ២៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងត្រៀមចុះហត្ថលេខាជាមួយនាយខណ្ឌរដ្ឋបាលជលផលនៅទីកន្លែង និងពេលវេលាដែលបានកំណត់។

### ប្រការ ១៩.-

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវបញ្ជាក់ពីចំនុចសំខាន់ៗដូចខាងក្រោម ៖

- ភាគីចុះកិច្ចព្រមព្រៀង
- ទំហំកន្លែងនេសាទ
- រយៈពេលគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទ
- លក្ខខណ្ឌនៃការគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទ

- លក្ខខណ្ឌនៃការប្រើប្រាស់ឧបករណ៍នេសាទ
- ឯកសារពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ២០.-**

ភាគីដែលត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះមានតែពីរប៉ុណ្ណោះគឺ នាយខណ្ឌរដ្ឋបាលជលផល និង គណៈកម្មការសហគមន៍នេសាទ ហើយត្រូវចុះហត្ថលេខាជាសាក្សីដោយក្រុមប្រឹក្សាឃុំ សង្កាត់សាមី ។ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួចហើយ ត្រូវមានបោះត្រាខណ្ឌរដ្ឋបាលជលផលលើគ្រប់សន្លឹកនៃកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា ។

## ជំពូកទី ៨
## ការចុះបញ្ជី និងការទទួលស្គាល់សហគមន៍នេសាទ

**ប្រការ ២១.-**

បន្ទាប់ពីការចុះកិច្ចព្រមព្រៀងសហគមន៍នេសាទ នាយខណ្ឌរដ្ឋបាលជលផលត្រូវស្នើសុំទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរដ្ឋបាលជលផលថ្នាក់កណ្តាល ដោយភ្ជាប់មកជាមួយនូវឯកសារនានាផ្អែកតាម មាត្រា ២៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ដើម្បីធ្វើការចុះបញ្ជីសហគមន៍នេសាទ និងប្រកាស ទទួលស្គាល់ ។

## ជំពូកទី ៩
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**ប្រការ ២២.-**

បន្ទាប់ពីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍របស់ខ្លួន ដោយផ្អែកតាមគំរូឧបសម្ព័ន្ធទី ៤ ភ្ជាប់ជាមួយប្រកាសនេះ ។

**ប្រការ ២៣.–**

មុននឹងរៀបចំធ្វើផែនការ គណៈកម្មការគប្បីធ្វើការសិក្សា និងប្រមូលព័ត៌មានឱ្យបានច្បាស់ មានជាអាទិ៍ ÷

- ស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដូចជាៈ ចំនួនប្រជាពលរដ្ឋ ជនជាតិ ប្រពៃណី សាសនា មុខរបរ ប្រាក់ចំណូល ករិតវប្បធម៌ ។ល។
- ស្ថានភាពនៃការនេសាទដូចជា ចំនួនអ្នកនេសាទនៅក្នុងសហគមន៍ អ្នកនេសាទមកពីក្រៅសហគមន៍ ឧបករណ៍នេសាទដែលប្រើប្រាស់ និងពេលវេលានៃការធ្វើនេសាទ
- លក្ខណៈរបស់ដែននេសាទដូចជា ចំនួន និងទំហំបឹង ត្រពាំង ព្រែក ស្ទឹង អូរ ទំនាបលិចទឹក អន្លង់ជំរកត្រី ឆ្នេរសមុទ្រ ព្រៃលិចទឹក ឬព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្ម
- សកម្មភាពពាក់ព័ន្ធនឹងការធ្វើនេសាទដូចជា វារីវប្បកម្ម ការកែច្នៃផលនេសាទ និងការផលិតឧបករណ៍នេសាទ
- ស្ថានភាពកសិកម្មដូចជា ដីស្រែ ចំការ ប្រភេទដំណាំ និងវិធីសាស្ត្រដាំដុះ និងការពារ ការចិញ្ចឹមសត្វ សិប្បកម្ម និងពាណិជ្ជកម្ម
- បញ្ហាដែលកើតមាននៅក្នុងសហគមន៍នេសាទពាក់ព័ន្ធវិស័យជលផលដូចជា បទល្មើសនេសាទ ការកាប់បំផ្លាញព្រៃលិចទឹក ។

**ប្រការ ២៤.–**

ផ្អែកលើព័ត៌មានដែលប្រមូលបាន គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំកិច្ចប្រជុំជាមួយសមាជិកសហគមន៍នេសាទទាំងអស់ ហើយអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗចូលរួម ដើម្បីធ្វើការពិភាក្សាអំពីការរៀបចំធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។ នៅក្នុងកិច្ចប្រជុំនេះ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំការពិភាក្សានូវចំណុចសំខាន់ៗដូចជា ÷

- បង្ហាញជូននូវព័ត៌មានដែលប្រមូលបាន ដើម្បីដាក់ជូនអង្គប្រជុំជ្រាប និងផ្តល់យោបល់បន្ថែម
- លើកឡើងនូវបញ្ហា និងតម្រូវការរបស់សហគមន៍នេសាទពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍ ដើម្បីដាក់ចេញនូវវិធានការ ឬរៀបចំជាផែនការសកម្មភាពជាក់លាក់ដើម្បីដោះស្រាយ
- លើកឡើងនូវការងារដែលត្រូវរៀបចំជាផែនការគ្រប់គ្រងសហគមន៍នេសាទសំរាប់រយៈពេល ៣ ឆ្នាំ ។

**ប្រការ ២៥.-**

បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធរួចមក គណៈកម្មការសហគមន៍នេសាទត្រូវធ្វើការសម្របសម្រួលនូវលទ្ធផលផែនការគ្រប់គ្រងដែលរៀបចំនោះ ដើម្បីដាក់បញ្ចូលជាមួយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**ប្រការ ២៦.-**

ដើម្បីបង្កភាពងាយស្រួលដល់ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំតារាងផែនការរួម ក្នុងនោះមានៈ ឈ្មោះផែនការសកម្មភាព លទ្ធផលរំពឹងទុក ការប៉ាន់ស្មានចំណាយប្រភពថវិកា ពេលចាប់ផ្តើម និងពេលបញ្ចប់។ ក្រៅពីតារាងផែនការរួមនេះ គណៈកម្មការត្រូវរៀបចំតារាងលំអិតភ្ជាប់ជាច្រើនទៀតដូចជា តារាងកម្មវិធីការងារ តារាងតម្រូវការពលកម្ម ឧបករណ៍សំភារៈ និងការចំណាយថវិកា។

**ប្រការ ២៧.-**

បន្ទាប់ពីបានធ្វើការពិភាក្សាយ៉ាងល្អិតល្អន់ជាមួយសមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗជាពិសេសមានការផ្តល់នូវមតិយោបល់ពីរដ្ឋបាលជលផលរួចមក គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំចងក្រងឯកសារផែនការគ្រប់គ្រងកន្លែងនេសាទសគមន៍របស់ខ្លួន ដើម្បីទុកជាឯកសារមូលដ្ឋានសម្រាប់ការអនុវត្ត ការត្រួតពិនិត្យ និងការតាមដានសកម្មភាពរបស់សហគមន៍នេសាទ។ ចំណុចសំខាន់ៗនៃឯកសារផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រួមមានៈ ទស្សនៈវិស័យ គោលបំណង យុទ្ធសាស្ត្រ និងតារាងផែនការនានា ជាពិសេសតារាងបញ្ជាក់ពីតម្រូវការ និងការចំណាយលំអិត ដោយយោងទៅតាមប្រភេទនៃចំនួនផែនការដែលលើកឡើង។ ឯកសារផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេះ ត្រូវដាក់ជូនមហាសន្និបាតសហគមន៍នេសាទធ្វើការអនុម័ត មុននឹងផ្ញើជូនរដ្ឋបាលជលផលថ្នាក់កណ្តាលដើម្បីពិនិត្យ និងសម្រេច។

**ប្រការ ២៨.-**

គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំយុទ្ធសាស្ត្រឱ្យបានសមស្រប ដោយបញ្ជាក់ពីយន្តការ និងវិធីសាស្ត្រឱ្យបានច្បាស់លាស់ដើម្បីតាមដាន និងអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឱ្យបានជោគជ័យ។

**ប្រការ ២៩.-**

បន្ទាប់ពីមហាសន្និបាតរបស់សហគមន៍នេសាទអនុម័តលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រួចហើយ តំណាងគណៈកម្មការសហគមន៍នេសាទត្រូវចុះហត្ថលេខា និងដាក់ស្នើផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍

ជូនទៅរដ្ឋបាលជលផលថ្នាក់កណ្តាលដើម្បីធ្វើការពិនិត្យ និងសម្រេចតាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ និងសមត្ថកិច្ចរដ្ឋបាលជលផល។ ក្រោយពីមានការពិនិត្យសម្រេចដោយរដ្ឋបាលជលផលថ្នាក់កណ្តាលរួចហើយ ឯកសារផែនការនោះត្រូវប្រថាប់ត្រារបស់រដ្ឋបាលជលផលថ្នាក់កណ្តាលជាសំគាល់នៅលើគ្រប់សន្លឹក។

**ប្រការ ៣០.–**

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អាចធ្វើការកែប្រែក្នុងករណីចាំបាច់។ គណៈកម្មការសហគមន៍នេសាទអាចធ្វើការពិគ្រោះយោបល់កែលំអនូវផែនការគ្រប់គ្រងសហគមន៍នេសាទ ដែលត្រូវធ្វើតាមរបៀបនៃការណែនាំ និងគំរូ ប៉ុន្តែត្រូវធ្វើសំណើសុំការឯកភាពយល់ព្រមពីរដ្ឋបាលជលផលថ្នាក់កណ្តាលដើម្បីអនុញ្ញាតលើការកែប្រែនោះជាមុនសិន ទើបយកមកអនុវត្តបាន។ បន្ទាប់ពីទទួលបានសំណើហើយ រដ្ឋបាលជលផលត្រូវឆ្លើយតប ក្នុងរយៈពេល ៣០ ថ្ងៃ។ ក្នុងករណីមិនឆ្លើយតបមានន័យថារដ្ឋបាលជលផលយល់ព្រមតាមសំណើរបស់សហគមន៍។

## ជំពូកទី ១០
## ការត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍

**ប្រការ ៣១.–**

ផ្នែករដ្ឋបាលជលផលត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងពង្រឹងការអនុវត្តន៍កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ព្រមទាំងធ្វើការវាយតម្លៃប្រចាំឆ្នាំដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការសហគមន៍នេសាទ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

ការវាយតម្លៃត្រូវមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ហើយត្រូវរៀបចំធ្វើរបាយការណ៍ស្តីពីលទ្ធផលត្រួត ពិនិត្យ និងវាយតម្លៃនោះ។ ក្នុងករណីដែលគណៈកម្មការសហគមន៍នេសាទពិនិត្យឃើញថា ការត្រួតពិនិត្យ និងវាយតម្លៃខាងលើជាការត្រឹមត្រូវ គណៈកម្មការសហគមន៍នេសាទត្រូវចុះហត្ថលេខាទទួលស្គាល់លើការត្រួតពិនិត្យ និងវាយតម្លៃនោះ។ ក្នុងករណីដែលគណៈកម្មការសហគមន៍នេសាទពិនិត្យឃើញថា ការត្រួតពិនិត្យ និងវាយតម្លៃខាងលើមិនត្រឹមត្រូវ គណៈកម្មការសហគមន៍នេសាទអាចផ្តល់ភស្តុតាងច្បាស់លាស់ ដើម្បីសុំធ្វើការកែតម្រូវឱ្យបានសមស្របឡើងវិញ ហើយបន្ទាប់មកត្រូវចុះហត្ថលេខាទទួលស្គាល់លើរបាយការណ៍លទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃនោះ។

**ប្រការ ៣២.–**

គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំរបាយការណ៍រៀងរាល់ ៣ ខែម្តង ជូនខណ្ឌរដ្ឋបាលជលផលតាមរយៈផ្នែករដ្ឋបាលជលផល និងចម្លងជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវរក្សាទុកនៅក្នុងគណៈកម្មការសហគមន៍នេសាទ។

គំរូរបាយការណ៍របស់សហគមន៍នេសាទ ត្រូវកំណត់ដោយរដ្ឋបាលជលផលដែលរៀបរាប់អំពីចំណុចសំខាន់ៗជាអាទិ៍ដូចខាងក្រោម ÷

- លទ្ធផលនៃការអនុវត្តន៍កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- លទ្ធផលនៃការអនុវត្តន៍ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សកម្មភាពរីកចំរើនរបស់សហគមន៍នេសាទ
- សង្ខេបអំពីស្ថានភាពចំណូល និងការចំណាយថវិការបស់គណៈកម្មការសហគមន៍នេសាទ
- បញ្ហាដែលបានជួបប្រទះ និងអនុសាសន៍សម្រាប់កែលំអ
- ទិសដៅ និងសកម្មភាពការងារសម្រាប់អនុវត្តក្នុងខែ ត្រីមាស ឆមាស និងឆ្នាំបន្ទាប់។

ផ្អែកលើរបាយការណ៍របស់សហគមន៍នេសាទ ខណ្ឌរដ្ឋបាលជលផលត្រូវធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។

## ជំពូកទី ១១
## ការដោះស្រាយវិវាទ

**ប្រការ ៣៣.–**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ ៣៤.–**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច។

## ជំពូកទី ១២
## ការរំសាយសហគមន៍នេសាទ

**ប្រការ ៣៥.–**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថាមានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្ដីសម្រេចរបស់មហាសន្និបាត ដោយមូលហេតុសហគមន៍នេសាទគ្មានសកម្មភាពក្នុងរយៈពេល ២ ឆ្នាំជាប់ៗគ្នា
- ការឯកភាពផ្ទៃក្នុងរបស់សមាជិកសហគមន៍នេសាទ។

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

**ប្រការ ៣៦.–**

គ្រប់កន្លែងនេសាទសហគមន៍ និងសហគមន៍នេសាទទាំងឡាយណាដែលបានបង្កើតឡើងនៅមុនពេលចូលជាធរមាននៃច្បាប់ស្ដីពីជលផល អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ និងប្រកាសស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទនេះត្រូវពិនិត្យរៀបចំបែបបទឡើងវិញ អនុលោមតាមច្បាប់ស្ដីពីជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធខាងលើ ក្នុងរយៈពេលមិនលើសពី ៣៦ ខែ គិតចាប់ពីថ្ងៃចេញប្រកាសនេះ។

## ជំពូកទី ១៤
## អវសានប្បញ្ញត្តិ

**ប្រការ ៣៧.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣៨.-**

អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ប្រធានរដ្ឋបាលជលផល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានសហគមន៍នេសាទត្រូវទទួលបន្ទុកអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ២០០៧

រដ្ឋមន្ត្រី

ចាន់.សារុន

**<u>កន្លែងទទួល</u>:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៣៨
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ ភ្ជាប់ប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៧

# គំរូ

# លក្ខន្តិកៈសហគមន៍នេសាទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚✿៛៛

# គំរូ

# លក្ខន្តិកៈសហគមន៍នេសាទ

.........................................

ឈ្មោះសហគមន៍នេសាទ:.........................................

ភូមិ :.........................................

ឃុំ /សង្កាត់ :.........................................

ស្រុក /ខណ្ឌ :.........................................

ខេត្ត /ក្រុង :.........................................

## ជំពូកទី ១
## គោលបំណង និងនាមករណ៍

**ប្រការ ១.–**

លក្ខន្តិកៈនេះមានគោលបំណង ៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ ។

**ប្រការ ២ .–**

ឈ្មោះសហគមន៍នេសាទ..........................................ហៅកាត់ថា...............................អាសយដ្ឋាន ផ្ទះលេខ...............ភូមិ.......................ឃុំ/សង្កាត់................ស្រុក/ខណ្ឌ..................ខេត្ត/ក្រុង.................. ។

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ៖

១. ភូមិ...............................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ......................................

២. ភូមិ...............................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ......................................

៣. ភូមិ...............................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ......................................

៤........................................................................................................................................

មានកម្មវត្ថុ ..............................................................................................................................

## ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.–**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- មានលំនៅដ្ឋាននៅក្នុងបណ្ដាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង ។

**ប្រការ ៤.–**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារ ស្របតាមច្បាប់ស្ដីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្ដឹងតវ៉ា ឬផ្ដល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅ សមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិក សហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី (៣) នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការ សហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ ។

**ប្រការ ៥.–**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ

- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន..............រៀល តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន...............រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៣
## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

### ប្រការ ៦.–

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ÷

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

### ប្រការ ៧.–

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម.
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។

# ជំពូកទី ៤
## របៀបរៀបចំកាន់បញ្ជី និង ឯកសារនានា

**ប្រការ ៨.–**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ÷

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៩.–**

រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ ÷

- ការចំណាយពី........រៀល ដល់...........រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី.........រៀល ដល់..........រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី.........រៀល ដល់ ..........រៀល ត្រូវសម្រេចដោយមហាសន្និបាត ។

**ប្រការ ១០.–**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ÷

- ចំណូល ចំណាយថវិកា
- សារពើភណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

**ប្រការ ១១.–**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ÷

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ

- រាល់ចរិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ចរិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២.-**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង ។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល ។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

**ប្រការ ១៣.-**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

**ប្រការ ១៤.-**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលប្រាំមួយ (៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

## ប្រការ ១៥.–

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាសជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

## ប្រការ ១៦.–

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀប រៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

## ប្រការ ១៧ .–

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ÷

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧
## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.-**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្ដីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្ដីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩.-**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្ដង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

**ប្រការ ២០.-**

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

**ប្រការ ២១.-**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំសង្កាត់ និងទីស្នាក់ការ

សហគមន៍នេសាទ

- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងជប់ (១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមាន វត្តមាន។

**ប្រការ ២២.–**

មហាសន្និបាតអនុម័ត ÷

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៨

## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.–**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

**ប្រការ ២៤.–**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ (៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥.–**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦.–**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទតាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩

## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧.–**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

- សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨.–**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩.–**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ។
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣០.–**

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន ។

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.–**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត ។ ការលើក

សំណើ កែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត ។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្ដាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.–**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី.........ខែ.........ឆ្នាំ២០០......និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅ...............ថ្ងៃទី........... ខែ.........ឆ្នាំ..........

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ឧបសម្ព័ន្ធទី ២ ភ្ជាប់ប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៧

# គំរូ

## បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៥៦

# គំរូ

## បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

..........................

## គំរូ

## បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ.................................... សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ÷

### ប្រការ ១._

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ ។

### ប្រការ ២._

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ÷

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីមិនព្រមសង ត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន ។

### ប្រការ ៣ ._

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន ៣ ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព ។

**ប្រការ ៤.–**

សិទ្ធិដាក់ទណ្ឌកម្ម ÷

**ក -គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍។

**ខ -មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន។

**ប្រការ ៥.–**

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈ ឧបករណ៍នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៦.–**

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទ ដូចមានចែងខាងក្រោម ÷

- មងប្រវែងមិនលើសពី.............................................ម៉ែត្រ
- អួនប្រវែងមិនលើសពី.............................................ម៉ែត្រ
- អញ្ចងប្រវែងមិនលើសពី.........................................ម៉ែត្រ
- ថ្នងទំហំមិនលើសពី...............................................ម៉ែត្រ

- សំណាញ់ប្រវែងមិនលើសពី........................................ម៉ែត្រ
- លាន់ចំនួនមិនលើសពី..................................................គ្រឿង
- ឡើចំនួនមិនលើសពី...................................................គ្រឿង
- ..........................................................................

**ប្រការ ៧.–**

សមាជិកសហគមន៍នេសាទដែល ÷

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផលត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹក ព្រៃកោងកាង ឬបំផ្លាញផ្កាថ្មឬស្មៅសមុទ្រ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការ នេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ៨.–**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ។

**ប្រការ ៩.–**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី.....ខែ.....ឆ្នាំ២០០.....និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅ................ថ្ងៃទី........... ខែ.........ឆ្នាំ...........

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ឧបសម្ព័ន្ធទី ៣ ភ្ជាប់ប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៧

# គំរូ

# កិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គំរូ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

ឈ្មោះសហគមន៍នេសាទ :.........................................
ភូមិ :.........................................
ឃុំ /សង្កាត់ :.....................................
ស្រុក /ខណ្ឌ :.....................................
ខេត្ត /ក្រុង :.....................................

# កិច្ចព្រមព្រៀង
## កន្លែងនេសាទសហគមន៍

រវាង

នាយខណ្ឌរដ្ឋបាលជលផល..........................ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាស័យដ្ឋាននៅៈ
....................................ទូរស័ព្ទលេខ...................អ៊ីម៉ែល.............ទូរសារលេខ................ហៅថា " ភាគី **ក** " ។

និង

ប្រធានគណៈកម្មការសហគមន៍នេសាទ..................................ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទ
ដែលមានអាសយដ្ឋានស្ថិតនៅៈ.......................................... ទូរស័ព្ទលេខ............................ហៅថា " ភាគី **ខ** " ។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម ៖

**ប្រការ ១.–**

ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី............ខែ............ឆ្នាំ..............រហូតដល់ថ្ងៃទី
.............ខែ..............ឆ្នាំ..........................ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ ។

**ប្រការ ២.–**

ដែននេសាទនេះមានឈ្មោះថា "កន្លែងនេសាទសហគមន៍ ............................................................"
ដែល លាតសន្ធឹងនៅក្នុង ៖

ភូមិ .....................................................ឃុំ សង្កាត់.........................................................
ភូមិ......................................................ឃុំ សង្កាត់ .......................................................
ភូមិ......................................................ឃុំ សង្កាត់.........................................................
ស្រុក ខណ្ឌ.............................................ខេត្ត ក្រុង.....................................................

មាននិយាមកាដូចខាងក្រោមៈ

..........................................................................................................................................
..........................................................................................................................................
...............................................................................................ដូចផែនទីដែលបានភ្ជាប់មកជាមួយ ។

**ប្រការ ៣.–**

ភាគី **ក** ត្រូវបំពេញភារកិច្ចជាអ្នកជួយសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

**ប្រការ ៤.–**

ភាគី **ខ** ត្រូវរៀបចំ :

- កន្លែងអភិរក្សព្រៃលិចទឹក ឬព្រៃកោងកាង
- កន្លែងអភិរក្សផ្កាថ្ម ឬស្មៅសមុទ្រ
- ស្រះ អាង អន្លង់ត្រីមេពូជ
- កន្លែងអភិរក្សជីវចំរុះ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

**ប្រការ ៥.–**

ភាគី **ខ** ត្រូវរៀបចំប្រជុំពិភាក្សាអំពីទំហំ ចំនួន ប្រវែង និងប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

**ប្រការ ៦.–**

ភាគី **ខ** មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម :

- ការពារព្រៃលិចទឹក និងព្រៃកោងកាងដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹកសម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក និងព្រៃកោងកាង ។

**ប្រការ ៧.–**

ភាគី ២ មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម ៖

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាផ្សោតជាដើម
- លើកទំនប់ លុប ឬជីក បឹង ព្រែក ប្រឡាយ រណ្តៅ បៀ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក ឬព្រៃកោងកាងក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធិ ឬវាតដីធ្វើស្រែចំការ ឬស្រែអំបិល ឬគោលបំណងផ្សេងៗឡើយ
- ធ្វើនេសាទ កាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬដាំសារាយដែលជាពូជនាំឱ្យខូចដល់បរិស្ថានធម្មជាតិ បំផ្លិចបំផ្លាញដល់ធនធានជលផល ឬបង្កអន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ ឬធ្វើអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃស្មៅសមុទ្រ ឬផ្កាថ្ម
- ប្រមូលផល ទិញ លក់ ដឹកជញ្ជូន និងធ្វើសន្និធិផ្កាថ្ម
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ឈិបយន្ត និងអួនអូសទឹកសាប
- ដាំ ឬថែរក្សាដំណាំឈូកក្នុងដែននេសាទ
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១.៥ សង្ទីម៉ែត្រ និងធំជាងដប់ប្រាំ(១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ។

**ប្រការ ៨.–**

ភាគី ២ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញ និងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូបឱ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជលផល ។

**ប្រការ ៩.–**

ភាគី ២ ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម ៖

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរដែលពាក់ព័ន្ធ។

**ប្រការ ១០.–**

ប្រសិនបើភាគី **ខ** មិនអនុវត្តតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ ១១.–**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្របសហគមន៍នេសាទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។

**ប្រការ ១២.–**

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង ២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ។

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធ ដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា។

ថ្ងៃទី........... ខែ ...........ឆ្នាំ ................

| **ភាគី ក** | **ភាគី ខ** |
|---|---|
| **នាយខណ្ឌរដ្ឋបាលជលផល..........** | **ប្រធានគណៈកម្មការសហគមន៍នេសាទ** |
| ហត្ថលេខា | ហត្ថលេខា |

**សាក្សី**

**មេឃុំ ចៅសង្កាត់** ..........................................

ហត្ថលេខា

# គំរូ

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គំរូ
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០...... ២០........)

ឈ្មោះសហគមន៍នេសាទ :......................................

ភូមិ :......................................

ឃុំ /សង្កាត់ :......................................

ស្រុក/ខណ្ឌ :......................................

ខេត្ត /ក្រុង :......................................

# គំរូផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

---

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ.........................................ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី...... ខែ........ឆ្នាំ ២០០....និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ២០០...។ សហគមន៍នេសាទ...........................................មានទីតាំងស្ថិតនៅក្នុងភូមិ.................................ឃុំ......... ......ស្រុក...................ខេត្ត.................. ដែល មានសមាជិកសរុបចំនួន ...........នាក់ ស្រីចំនួន..........នាក់ និងមានគណៈកម្មការចំនួន..........នាក់ ស្រីចំនួន .........នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន............គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ...................................... ..........................................................................................................................................។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាជនរស់នៅ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន................នាក់ប្រុស..............នាក់ ស្រី...........នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន.......នាក់ ខ្មែរឥស្លាមចំនួន........នាក់ អាណិកជនវៀតណាមចំនួន........នាក់ ...............................។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន....................នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន........................នាក់ ស្រី ...... នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន........................នាក់ ស្រី ...... នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន....................នាក់ ស្រី ....... នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទ មាន.............នាក់ ស្រី ....... នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ..............%។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាម ប្រមាណ ...............% សាសនាកាតូលិកប្រមាណ................%
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន............នាក់ ស្រី.........នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន..........................នាក់ ស្រី ...................នាក់ កំរិតមធ្យមសិក្សាចំនួន.................នាក់ ស្រី ............នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ............នាក់ ស្រី ............នាក់

**ខ -មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន..............គ្រួសារ
- ធ្វើស្រែចំនួន ..................គ្រួសារ ទំហំ .........ហិកតា
- ធ្វើវារីវប្បកម្មចំនួន ..........គ្រួសារ ទំហំ.........ហិកតា ឬចំនួន.......បែ
- ដាំបន្លែចំនួន ...................គ្រួសារ ទំហំ ........ហិកតា
- ជាងផ្ទះចំនួន ...................គ្រួសារ
- ធ្វើចំការចំនួន ..................គ្រួសារ ទំហំ ........ហិកតា
- ធ្វើសិប្បកម្មចំនួន .............គ្រួសារ
- ដាំសារាយចំនួន ...............គ្រួសារ ទំហំ ........ហិកតា
- លក់ដូរ ចំនួន ....................គ្រួសារ
- កែច្នៃផលនេសាទ ............គ្រួសារ
- .................................................................

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍............................................ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ............ ......... .ឬ/និង ដែននេសាទទឹកសាប ឬដែននេសាទតំបន់ឆ្នេរសមុទ្រ។

កន្លែងនេសាទសហគមន៍................................មានទំហំ.....................ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង ........................................................................................
- ខាងត្បូងទល់នឹង ........................................................................................
- ខាងកើតទល់នឹង........................................................................................
- ខាងលិចទល់នឹង........................................................................................
- ........................................................................................................

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍..............................................មានបឹងចំនួន..............................

ព្រៃកចំនួន........................ ប្រឡាយចំនួន...................... ត្រពាំងចំនួន.................. បឹងចំនួន............................
និង.......................................................... ។

- បឹងឈ្មោះ ............................ទំហំ .....................នេសាទពីខែ.................ដល់ខែ ....................
- ទន្លេឈ្មោះ ..........................ទំហំ .....................នេសាទពីខែ.................ដល់ខែ ....................
- អូរឈ្មោះ ............................ទំហំ .....................នេសាទពីខែ.................ដល់ខែ ....................
- ព្រែកឈ្មោះ...........................ប្រវែង...................នេសាទពីខែ................ដល់ខែ ....................
- ប្រឡាយឈ្មោះ........................ប្រវែង...................នេសាទពីខែ................ដល់ខែ ....................
- ស្ទឹងឈ្មោះ............................ប្រវែង ...................នេសាទពីខែ ..............ដល់ខែ ....................
- ត្រពាំងឈ្មោះ..........................ទំហំ.......................នេសាទពីខែ ..............ដល់ខែ ....................
- ........................................................................................................................................
- អាងទឹកឈ្មោះ........................ទំហំ.......................នេសាទពីខែ.................ដល់ខែ....................
- ស្រះឈ្មោះ............................ទំហំ...................... នេសាទពីខែ ................ដល់ខែ....................
- បឹងចំនួន.............................. ឈ្មោះ....................នេសាទពីខែ ................ដល់ខែ....................
- ព្រៃលិចទឹក/ព្រៃកោងកាងមានទំហំសរុប ទំហំ..............ហិកតា
- ព្រៃឈ្មោះ ..........................................ទំហំ ............ហិកតា
- ព្រៃឈ្មោះ ..........................................ទំហំ ............ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប .....................................ហិកតា ។

## ឆ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- បឹងឈ្មោះ................ទំហំ........................ហិកតា ( បណ្ដោយ .......... ម ទទឹង ..........ម)
- អន្លង់ឈ្មោះ..............ទំហំ........................ហិកតា ( បណ្ដោយ .......... ម ទទឹង ..........ម)
- ស្រះឈ្មោះ...............ទំហំ........................ហិកតា ( បណ្ដោយ .......... ម ទទឹង ..........ម)
- ព្រៃឈ្មោះ................ទំហំ........................ហិកតា ( បណ្ដោយ .......... ម ទទឹង ..........ម)
- ទន្លេឈ្មោះ................ទំហំ........................ហិកតា ( បណ្ដោយ .......... ម ទទឹង ..........ម)
- កោះឈ្មោះ................ទំហំ........................ហិកតា ( បណ្ដោយ .......... ម ទទឹង ..........ម)
- ........................................................................................................................................

**ឃ. ធនធានជលផល**

- ប្រភេទត្រី ( ត្រីរស់ ឆ្តោ រៀល.................)
- ប្រភេទវារីសត្វ ( អណ្តើក ពស់ ក្តាម...........)
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (រាំង ត្រស់ ត្នួ..........ព្រលិត ត្រកួន..............)

(ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី.........ភ្ជាប់មកជាមួយ) ។

## ៤. ការធ្វើនេសាទ

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន..............................នាក់ ស្រី ,........ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន.................នាក់ ស្រី ......... នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន........................នាក់ ស្រី ......... នាក់

**ខ. ឧបករណ៍នេសាទ**

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទៈ

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ (ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | | | | |
| អួន | | | | |
| សន្ទូចរនង | | | | |
| លប | | | | |
| ...................... | | | | |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| | | | |
| | | | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | | | |
| អួន | | | |
| សន្ទូចរនង | | | |
| លប | | | |
| ............................ | | | |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| | | | |
| | | | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | | | |
| អួន | | | |
| សន្ទូចរនង | | | |
| លប | | | |
| ............................ | | | |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (*គិតជា គក*) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | | | |
| ក្តាម ខ្យង | | | |
| បង្គា | | | |
| ……… | | | |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ ………………………មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវជំនោរឡើង នាទីព្រៃលិចទឹក និងព្រៃកោងកាង និងកន្លែងនេសាទតាមឆ្នេរ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| | | | | | |
| | | | | | |

**គ.២ ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

**គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

**គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក**

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក | | | | | | |
| ២-ថែរក្សា និងរំលោះព្រៃលិចទឹក | | | | | | |
| ..................... | | | | | | |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| បែរ | | | | ចាប់ផ្ដើម | ប្រមូលផល |
| ស៊ង | | | | | |
| ស្រះ | | | | | |
| ............... | | | | | |

### គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | | | | | |
| ភាគទានប្រចាំឆ្នាំ | | | | | |
| ជំនួយសប្បុរសជន និងអង្គការនានា | | | | | |
| ................................ | | | | | |

### គ-៧ ផែនការផ្សេងៗទៀត........

### ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា:ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍................រយៈពេល ៣ ឆ្នាំ (២០០.........ដល់ ២០០............)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | |
| ២. ការកែលំអផែននេសាទ | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | |
| ៤-ផែនការគ្រប់គ្រង ព្រៃលិចទឹក | | | | | | | |
| ៥- ផែនការអភិវឌ្ឍវារីវប្បកម្ម | | | | | | | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | | | | | | | |
| ៧- ......................... | ...... | ...... | ...... | ...... | ...... | | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០០...... | | | | | | | | | | | | ២០០...... | | | ២០០...... | | |
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ... | ធ្នូ | មករា | ... | ធ្នូ |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| ១.១ ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | |
| ១.២ | | | | | | | | | | | | | | | | | | |
| ២........................................ | | | | | | | | | | | | | | | | | | |
| ២.១.................................. | | | | | | | | | | | | | | | | | | |
| ២.២.................................. | | | | | | | | | | | | | | | | | | |
| ៣........................................ | | | | | | | | | | | | | | | | | | |

ថ្ងៃទី ...... ខែ ......... ឆ្នាំ........

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**តាមរយៈ មេឃុំ ឬចៅសង្កាត់** ..............................

ហត្ថលេខា

លេខៈ ........................ ជផ

បានឃើញ និងឯកភាព

ថ្ងៃទី ......... ខែ .......... ឆ្នាំ ..............

**ប្រធានរដ្ឋបាលជលផល**

ការបោះពុម្ពសៀវភៅនេះ ធ្វើឡើងក្រោមជំនួយរបស់សហភាពអឺរ៉ុប
This publication is funded by the European Union